# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ០៣៦/១១ គ.ជ.ប

# សេចក្តីជូនដំណឹង

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- យោងសេចក្តីសម្រេចលេខ ០០១/០១១១/ពស/ស.វ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១១ របស់ព្រឹទ្ធសភា ស្តីពីការកំណត់កាលបរិច្ឆេទនៃការបោះឆ្នោត ការកំណត់ចំនួនអាសនៈ និងការបែងចែកអាសនៈតាមភូមិភាគ សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣
- យោងសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមជូនដំណឹងជាសាធារណៈដល់គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេសជ្រាបថា កាលបរិច្ឆេទនៃការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ ត្រូវប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ទី២៩ ខែមករា ឆ្នាំ២០១២ ខាងមុខនេះ។

ចំនួនអាសនៈទាំងអស់របស់ព្រឹទ្ធសភា សម្រាប់នីតិកាលទី៣ មានចំនួន ៦១ (ហុកសិបមួយ)។

ចំនួនអាសនៈរបស់ព្រឹទ្ធសភា សម្រាប់នីតិកាលទី៣ ដែលត្រូវបោះឆ្នោតជ្រើសតាំង ត្រូវកំណត់ត្រឹម ៥៧ (ហាសិបប្រាំពីរ)។ ចំនួនអាសនៈ តាមភូមិភាគ មានដូចខាងក្រោម ៖

- ភូមិភាគទី ១ រាជធានីភ្នំពេញ មាន ៦ អាសនៈ
- ភូមិភាគទី ២ ខេត្តកំពង់ចាម មាន ៨ អាសនៈ
- ភូមិភាគទី ៣ ខេត្តកណ្តាល មាន ៥ អាសនៈ
- ភូមិភាគទី ៤ ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងខេត្តប៉ៃលិន មាន១០ អាសនៈ
- ភូមិភាគទី ៥ ខេត្តតាកែវ កំពត និងខេត្តកែប មាន ៧ អាសនៈ
- ភូមិភាគទី ៦ ខេត្តព្រៃវែង និងខេត្តស្វាយរៀង មាន ៧ អាសនៈ
- ភូមិភាគទី ៧ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង និងខេត្តព្រះសីហនុ មាន ៨ អាសនៈ
- ភូមិភាគទី ៨ ខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី និងខេត្តមណ្ឌលគិរី មាន ៦អាសនៈ

អាស្រ័យដូចបានជំរាបជូនខាងលើនេះ សូមគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងប្រជាពលរដ្ឋកម្ពុជានៅទូទាំងប្រទេសជ្រាបជាព័ត៌មាន និងសហការជំរុញឱ្យដំណើរការរៀបចំការបោះឆ្នោតសម្រេចបានជោគជ័យ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០១១

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម_សូស្តី